**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ: ៣២៤
ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ ២០០៤
**<u>សាលដីកា</u>**
លេខ: ១៧៩
ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០៥

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៩ ខែសីហា ឆ្នាំ ២០០៥ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម ........... ជាប្រធាន
២-លោក ............. ជាចៅក្រម
៣-លោក ................. ជាចៅក្រម
៤-លោក ................ ជាចៅក្រមរបាយការណ៍
៥-លោក .................. ជាចៅក្រម

**<u>ក្រឡាបញ្ជី</u>**
-លោក ..................

**<u>តំណាងមហាអយ្យការ</u>**
-លោក ............. ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីកា ១៧(ង) ចុះថ្ងៃទី០២ខែមិថុនា ឆ្នាំ២០០៤នៃសំណុំរឿងរដ្ឋប្បវេណីលេខ២៤៨ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍រវាង:

**-ដើមចោទ**

១-ឈ្មោះ សសវណរ ជាចុងបញ្ជឹងសាទុក្ខ ភេទប្រុស អាយុ៣២ឆ្នាំជាតិខ្មែរ របររកស៊ីធ្វើការនៅក្រសួងសុរិយោដី មានទីលំនៅសព្វថ្ងៃផ្ទះលេខ១៦១E២ សង្កាត់មិត្តភាព ខ័ណ្ឌ៧មករា ក្រុងភ្នំពេញឪពុកឈ្មោះសុខ ឡេង (រ) ម្តាយឈ្មោះជ័ ខុន(រ)ប្រពន្ធឈ្មោះឃ្លោក វិចិត្តលត្តិណា មានកូន០៤នាក់ ។

២-ឈ្មោះដស ជាចុងបណ្តឹងសាទុក្ខ ភេទប្រុស អាយុ៤៦ឆ្នាំរបររកស៊ីនាយកទទួលបន្ទុកការងារសន្តិសុខនៃនាយកដ្ឋានចំការកៅស៊ូចំការអណ្តូង ស្រុកចំការលើ ខេត្តកំពង់ចាម ឪពុកឈ្មោះសំ រិ(រ) ម្តាយឈ្មោះដួង លៀម (រ) ប្រពន្ធឈ្មោះសុខ សុខេន មានកូន០៥នាក់ ។

-ចុងចម្លើយឈ្មោះ សបហ(ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ ឆ្នាំ ជាតិខ្មែរ របររកស៊ីប្រធានក្រុមហ៊ុនសុវណ្ណរតនៈ ទីលំនៅភូមិថ្នល់បែកខាងកើត ឃុំស្វាយទាប ស្រុកចំការលើ ខេត្ត
កំពង់ចាម ។

-មានលោក................ជាមេធាវីការពារ និង ជាតំណាង ។

**<u>កម្មវត្ថុ:</u>** ប្តឹងទាមទារប្រាក់ចំនួន១៥.០០០ដុល្លារអាមេរិក ។

បានឃើញបណ្តឹងសាទុក្ខលេខ២៩៦ ចុះថ្ងៃទី០៥ខែសីហាឆ្នាំ២០០៤របស់ឈ្មោះសបហាប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ១៧(ង)ចុះថ្ងៃទី០២ខែមិថុនាឆ្នាំ២០០៤របស់សាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៣២៤ចុះថ្ងៃទី០១ខែកញ្ញាឆ្នាំ២០០៤របស់តុលាការកំពូល។

តាមពាក្យបណ្តឹង ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០២ របស់ឈ្មោះសុខ សុវណ្ណារិទ្ធ និង ដស ប្តឹងទារប្រាក់ចំនួន១៥០០០ដុល្លា ការប្រាក់៣%ក្នុងមួយខែ ពីឈ្មោះសបហាដោយសំអាងហេតុថា កាលពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០០ ខ្លួន និង ខៀវ ស៊ុន ជាតំណាងឱ្យក្រុមហ៊ុនសុវណ្ណារតនៈ បានធ្វើកិច្ចសន្យាលក់ទិញអុសកៅស៊ូចំនួន២០០ហិកតា នៅចំការកៅស៊ូចំការអណ្តូង ហើយក្រុមហ៊ុនទាមទារឱ្យកក់ប្រាក់ចំនួន១៥.០០០ដុល្លា ដោយសន្យាយ៉ាងយូរបំផុតក្នុងអំឡុងខែ១១ ឆ្នាំ២០០០ ។

ប៉ុន្តែមកដល់ពេលនេះក្រុមហ៊ុនមិនទាន់ឱ្យខ្លួនចុះធ្វើអាជីវកម្មតាមកិច្ចសន្យា ខ្លួនបានទាមទារប្រាក់កក់នេះវិញជាញឹកញាប់ តែត្អូញត្អែរគ្មានលុយឱ្យខ្លួន រង់ចាំក្រុមហ៊ុនបង្វិលប្រាក់ឱ្យបាន។ ផ្ទុយទៅវិញ ក្រុមហ៊ុននេះបានយកប្រាក់របស់ខ្លួនទៅទិញកៅស៊ូពីប្រជាពលរដ្ឋមកកែច្នៃនាំចេញពុំព្រមបង្វិលប្រាក់កក់ ឱ្យខ្លួនវិញទេ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ១៧៦(ក) ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០២ របស់តុលាការ ខេត្តកំពង់ចាម ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០២ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ និងគតិច្បាប់ ។

២-ទទួលស្គាល់កិច្ចសន្យាលក់ និងទិញអុសលើកៅស៊ូ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០០ រវាងក្រុមហ៊ុនសុវណ្ណារតនៈ ជាអ្នកលក់ ហៅកាត់ថាភាគី(ក) និង អ្នកទិញឈ្មោះសុខ សុវណ្ណារិទ្ធ និង ដួងស្រួច ហៅកាត់ថា ភាគី(ខ) ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ និង គតិច្បាប់ (តាមមាត្រា៣ នៃក្រឹត្យច្បាប់ លេខ៣៨ ស្តីពីកិច្ចសន្យ) ។

៣-ឱ្យឈ្មោះសបហាសងប្រាក់ចំនួន១៥០០០$ (មួយម៉ឺនប្រាំពាន់ដុល្លាអាមេរិក) និងការប្រាក់៥%ក្នុង១ឆ្នាំ គិតពីថ្ងៃទី០៦ ខែកញ្ញាឆ្នាំ២០០០ ដល់ថ្ងៃសងប្រាក់គ្រប់ចំនួន ព្រមទាំងជម្ងឺចិត្តចំនួន៥.០០០$ ឱ្យទៅឈ្មោះសុខ សុវណ្ណារិទ្ធិ និង ឈ្មោះដស ការទាមទារលើសពីនេះរបស់សសវណារ និង ដស លើកចោល ។ តាមមាត្រា២២ និង ៥៩ នៃក្រឹត្យច្បាប់លេខ៣៨ ស្តីពីកិច្ចសន្យា ។

៤-នៅពេលដែលសាលក្រមនេះចូលជាស្ថាពរ បើឈ្មោះសបហាមិនព្រមសងប្រាក់ទៅឈ្មោះសុខ សុវណ្ណារិទ្ធ និង ឈ្មោះដស ទេតុលាការនឹងរឹបអូសទ្រព្យសម្បត្តិជាចលនវត្ថុនិង អចលនវត្ថុ របស់ឈ្មោះសបហានិងប្រពន្ធមកលក់ឡាយឡុង ដើម្បីសងប្រាក់ទៅដើមចោទក្នុងករណីសងមិនគ្រប់ត្រូវរឹបអូសទ្រព្យសម្បត្តិដែលបានកត់ត្រាកាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០២ របស់ឈ្មោះសបហាបន្ថែមទៀតដើម្បីសងប្រាក់ទៅដើមចោទឲ្យទាល់តែគ្រប់ចំនួនករណីមានឧបាយកលទុច្ចរិត តុលាការនឹងចាប់បង្ខំឈ្មោះសបហាដាក់គុក៨ខែ ។ តាមមាត្រា២៤ នៃក្រឹត្យច្បាប់ លេខ៣៨ ស្តីពីកិច្ចសន្យា និងមាត្រា១៣៣ នៃច្បាប់ស្តីពីនីតិវិធី អនុវត្តសាលក្រមរដ្ឋប្បវេណី ។

៥-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន៧.០០០៛ ដែលដើមចោទបានបង់ទុករួច ។ ពេល សាលក្រមស្ថាពរ បង្គាប់ឱ្យចុងចម្លើយបង់សងវិញ និង ឱ្យចុងចម្លើយបង់ពន្ធសមាមាត្រ១% លើប្រាក់ ដែលត្រូវសង ។

៦-សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខដើមចោទកំបាំងមុខចុងចម្លើយ សម្រេចបើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០២ របស់ឈ្មោះសបហាប្តឹមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ១៧៦(ក) ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០២ របស់តុលាការខេត្ត កំពង់ចាម ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ២៤៤(ក) ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០២ របស់តុលាការ ខេត្តកំពង់ចាម ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១-ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០២ របស់ដើមបណ្តឹងទាស់ ឈ្មោះសបហាទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-រក្សាទុកសាលក្រមកំបាំងមុខលេខ១៧៦(ក) ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០២ របស់តុលាការខេត្តកំពង់ចាម ទុកជាបានការពេញទាំងមូល ។

៣-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ តែចាត់ទុកជាចំពោះមុខ សម្រេចបើកផ្លូវឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ០៤ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៣ របស់ឈ្មោះសបហាប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ២៤៤(ក) ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០២ របស់តុលាការ ខេត្តកំពង់ចាម ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១៧(ង) ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៣ របស់ឈ្មោះ សបហាទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ២៤៤(ក) ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០២ របស់តុលាការខេត្តកំពង់ចាម ទុកជាបានការ ។

៣-កាត់យកប្រាក់ប្រដាប់ក្តីនៅជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀល ដែលឈ្មោះ សបហាបានបង់រួចហើយ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង២,៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះ៥.០០០រៀល និង លើអាជ្ញាធរតុលាការ៥.០០០រៀល។

៤-សាលដីកានេះជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខដើមចោទកំបាំងមុខចុងចម្លើយ។

បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ២៩៦ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៤ របស់ឈ្មោះសបហាប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ១៧(ង) ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសារណា ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៤ របស់ឈ្មោះសបហ។

បានឃើញសារណាឆ្លើយតប ចុះថ្ងៃ១៧ ខែមករា ឆ្នាំ២០០៥ របស់ឈ្មោះដស និង ឈ្មោះ សុខ សុវណ្ណរិទ្ធ ។

បានឃើញសារណាបន្ថែមចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៥ របស់ឈ្មោះដស និង ឈ្មោះ សូខ សូវណ្ណរិទ្ធ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា ៖ រឿងនេះជារឿងប្តឹងទាមទារប្រាក់ សូមក្រុមប្រឹក្សាជំនុំជំរះពិចារណា និង សំរេចតាមច្បាប់ ។

បានស្តាប់ក្រឡាបញ្ជីអានសារណារបស់លោកសបហ(ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលសវនាការ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ដស (ជាចុងបណ្តឹងសាទុក្ខ) នៅពេលសវនាការថា ដើមឡើយ លោកសបហគាត់ទាមទារប្រាក់កក់៥.០០០ដុល្លាអាមេរិក លុះដល់ពេលគ្រប់ចំនួនទឹកប្រាក់គាត់ចុះកិច្ចសន្យាជាមួយខ្លួន ។ ហើយការទៅកាប់អុសកៅស៊ូ ក្រុមហ៊ុនសុវណ្ណរតនៈមិនបានឲ្យអុសកៅស៊ូមកខ្លួនទេ ដោយឲ្យជំនារកៅស៊ូមកឲ្យខ្លួន ។ ខ្លួនសុំឲ្យលោក សេង ប៊ុនហេងសង់ប្រាក់មកឲ្យខ្លួនវិញ។ ដើម្បីកុំឲ្យខាតពេលវេលាយូរខ្លួនសុខចិត្តដកប្រាក់២.៤៨៨ដុល្លាអាមេរិកក្នុងចំនួនទឹកប្រាក់១៥.០០០ដុល្លាអាមេរិក ។

បានស្តាប់ចម្លើយរបស់ឈ្មោះ សសវណរ (ជាចុងបណ្តឹងសាទុក្ខ) នៅពេលសវនាការថា កាលនោះដោយខ្លួនមានទំនុកចិត្តលើប្អូនថ្លៃរបស់ខ្លួនឈ្មោះ ដស ឲ្យគាត់ជួយចាត់ចែងក្នុងការទិញឈើអុសកៅស៊ូក្រុមហ៊ុនសុវណ្ណរតនៈ ។ ខ្លួនបានចុះទៅដល់រោងចក្រលោកសបហាហើយរោងចក្ររបស់លោក សបហាមិនបានកាប់អុសកៅស៊ូឲ្យភាគីខ្លួនឡើយ ។ ខ្លួនចាំយូរៗទៅ ក្រុមហ៊ុនសូវណ្ណរតនៈ គឺគ្មានដំណើរការសោះ ។៉ ខ្លួនសុខចិត្តដកប្រាក់២៤៨៨ដុល្លាអាមេរិក ចេញពីប្រាក់ ១៥.០០០ដុល្លាអាមេរិក និង សុំឱ្យតុលាការកំពូលតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកលឹម ច័ន្ទប៊ុនកែវ ជាមេធាវីការពារ និងតំណាងឱ្យចុងចម្លើយ នៅពេលសវនាការថា យោងទៅតាមសំណុំរឿងអង្គហេតុមានការស៊ីសង្វាក់គ្នាមួយចំនួនទៅហើយ ។ កាលពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០០ លោក សុខ សុវណ្ណរិទ្ធ និង លោកដស បានចុះកិច្ចសន្យាជាមួយ ក្រុមហ៊ុនសុវណ្ណរតនៈស្តីពីការលក់និងទិញឈើអុសកៅស៊ូនៅក្នុងចំការរបស់ក្រុមហ៊ុនសុវណ្ណរតនៈ ។ លុះដល់ពេលកាប់ដើមកៅស៊ូ ភាគីក្រុមហ៊ុនសុវណ្ណរតនៈបានហៅលោកដស ឱ្យមកទទួលយកអុសឈើកៅស៊ូ ស្រាប់តែភាគីលោកដស បែរជាមិនព្រមទទួលអុសនៅចំការកៅស៊ូតាមកិច្ចសន្យាឡើយ ។ កន្លងមកដូចឯកសារដាក់ជូនតុលាការ សុទ្ធតែមានវិក័យប័ត្រត្រឹមត្រូវយកពីជំនាឈើ ពីក្រុមហ៊ុនសុវណ្ណរតនៈ ហើយគាត់បានយកប្រាក់កក់របស់គាត់វិញមួយចំនួនហើយ។ ម្យ៉ាងទៀតចំពោះចម្លើយរបស់លោកដស ថាកូនក្តីខ្លួនគ្មានកៅស៊ូនេះ វាខុសហើយ ហើយវាមានដំណើការហូតដល់សព្វថ្ងៃនេះ ។ ចំពោះ ការប្រាក់៥%ក្នុងមួយឆ្នាំ គឺជាការយល់ខុសរបស់តុលាការថ្នាក់ក្រោម និង សាលាឧទ្ធរណ៍ ដូច្នេះសូមឱ្យ ក្រុមប្រឹក្សាជំនុំជំរះតុលាការ

ពិចារណាលើចំនុចនេះ ។ ខ្លួនសូមសំណូមពរសូមឲ្យក្រុមប្រឹក្សាជំនុំជំរះ បដិសេធសាលដីការដ្ឋប្បវេណីលេខ១៧(ង) ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ទុកជា អសារបង់ ។

-ក្រោយពីបានស្តាប់របាយការណ៏ របស់ចៅក្រមរបាយការណ៏

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណាចុងចម្លើយ ចម្លើយដើមចោទ និងសេចក្តីសន្និដ្ឋានការពាររបស់ មេធាវីចុងចម្លើយ.

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២៩៦ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៤ របស់លោកសេង ប៊ុនហេងធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ក៏ដូចតុលាការខេត្តកំពង់ចាមដែរ ដែលបានសម្រេចឲ្យលោកសបហាសងប្រាក់ចំនួន១៥.០០០ដុល្លាអាមេរិក ទៅឱ្យលោកសុខ សុវណ្ណរិទ្ធ និង លោកដស ដោយអាងហេតុថា លោកសេង ប៊ុនហេងពុំទាន់បានទូទាត់ឱ្យលោកសសវណរ និងលោកដូងស្រួចនោះ គឺជាការភ័ន្តច្រឡំ ពីព្រោះថា:

-ក្នុងសារណា ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៤លោកសបហាបានអះអាងថា លោកបានសងប្រាក់តាមរយៈលោកដស ចំនួន២៤៨៨ដុល្លាអាមេរិក រួចហើយ។ ហើយតាមសារណាបន្ថែមចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៥ លោកសុខសុវណ្ណរិទ្ធ និងលោកដស សំណូមពរសុំកុំឱ្យអូសបន្លាយពេលវេលា ខ្លួនយល់ព្រមកាត់ប្រាក់ចំនួន២៤៨៨ដុល្លា លើទឹកប្រាក់១៥០០០ដុល្លាអាមេរិក តាមការអះអាងរបស់លោកសបហាតុលាការកំពូលគប្បីសម្រេចតាមការព្រមព្រៀងរបស់គូភាគី ។

-យល់ឃើញថា ការដែលចុងចម្លើយនិង មេធាវីចុងចម្លើយលើកឡើងក្នុងសារណានិងក្នុងពេល សវនាការថាចុងចម្លើយមានដើមកៅស៊ូហើយ ប៉ុន្តែដើមចោទមិនព្រមមកទទួលយកដើមកៅស៊ូទេ ដោយដើមកៅស៊ូចុះថ្លៃខ្លាំងនោះពុំមានភស្តុតាងបញ្ជាក់គួរឱ្យជឿបានទេ ។

-យល់ឃើញថា ការដែលតុលាការខេត្តកំពង់ចាម និង សាលាឧទ្ធរណ៏សម្រេចដាក់គុកបង្ខំលើរូបកាយដែលជានីតិបុគ្គលតំណាងឱ្យក្រុមហ៊ុនសុវណ្ណរតនះនោះ ជាការពុំត្រឹមត្រូវទេ ប៉ុន្តែដើម្បីចៀសវាងការអូសបន្លាយពេលវេលា និងធ្វើឱ្យសំណុំរឿងកាន់តែកកស្ទះច្រើន គប្បីតុលាការកំពូលសម្រេចទុកជាមោឃៈដោយឥតបង្វិល ។

-យល់ឃើញថា ក្នុងចម្លើយបានធ្វើសារណាជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមនាសវនាការនេះទេ មានតែមេធាវីមកចូលរួម ដូចនេះតុលាការកំពូលជំនុំជំរះកំបាំងមុខចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ១៧(ង) ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៤ របស់ សាលាឧទ្ធរណ៏ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ហើយ លើកលែងតែចំណុចស្តីពី ឲ្យឈ្មោះសបហាសងប្រាក់កក់ចំនួន១៥០០០ដុល្លាអាមេរិក ឱ្យទៅឈ្មោះ សុខ សុវណ្ណរិទ្ធនិងឈ្មោះដស ដែលត្រូវកែប្រែពី

១៥.០០០ដុល្លាមេរិក ដក២៤៨៨ដុល្លាអាមេរិក នៅសល់១២.៥១២ដុល្លាអាមេរិកវិញ តាមការទទួលស្គាល់របស់គួភាគី ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ**

**ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១-ទទួលបណ្តឹងសាទុក្ខលេខ២៩៦ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៤ របស់លោកសេង ប៊ុនហេងទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែអំពីតតិច្បាប់ត្រូវខ្លះខុសខ្លះ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ១៧(ង) ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ទុកជាបានការលើកលែងចំណុចស្តីពីឱ្យឈ្មោះសបហសងប្រាក់កក់ចំនួន១៥.០០០ដុល្លាអាមេរិកដែលត្រូវកែប្រែទៅជា១២៥១២ដុល្លាអាមេរិកវិញ និងសម្រេចទុកជាមោឃៈដោយឥតបង្វិលត្រង់ចំណុចដាក់គុកបង្ខំលើរូបកាយចុងចម្លើយចំនួន៨ខែ ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩០០០៛ ដែលលោកសបហបានបង់គឺ :

- ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ . r

-ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល. បង្គាប់ឲ្យ លោកសបហបង់ពន្ធសមាមាត្រមួយភាគរយលើទឹកប្រាក់ដែលត្រូវសងទៅ ឱ្យលោកសុខ សុវណ្ណរិទ្ធ និង លោកដស ។

៤-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០៥ ។